**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែមករា ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងខែមករា ឆ្នាំ២០១៦នេះ ស្ថានភាពទឹកទន្លេស្រកលឿនជាងបណ្តាឆ្នាំមុនៗ។ បច្ចុប្បន្ននៅស្ថានីយចតុមុខ ទឹកមានកម្ពស់២,៣៥ម ប្រៀបធៀបពេលដូចគ្នាឆ្នាំ២០១៥ ទន្លេចតុមុខមានកម្ពស់២,៦៣ម។

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងមានសន្ទុះលឿនជាងឆ្នាំមុន ដោយសម្រេចបានចំនួន៤៨៣.១៥៥ហិកតា ស្មើនឹង១១៥,៧៧% នៃផែនការ៤១៧.៣២៥ហិកតា លើសឆ្នាំមុនចំនួន៤.០៩១ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា ហើយប្រជាកសិករបាននឹងកំពុងដំណើរការប្រមូលផលជាបណ្តើរៗដោយទទួលបានបរិមាណផលសរុបចំនួន៥៧៧.៣៥៥តោន និងទិន្នផលជាមធ្យម៤,៣២៧តោន/ហិកតា។ ទន្ទឹមនឹងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងបន្តជំរុញការណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀតដែរ ព្រមទាំងជួយអប់រំណែនាំប្រជាកសិករឲ្យបន្តយកចិត្តទុកដាក់អំពីការបាត់បង់បរិមាណនិងគុណភាពផលស្រូវមុននិងក្រោយពេលប្រមូលផល រៀបចំរក្សាទុកដាក់ផលស្រូវឲ្យបានល្អ ដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារ ការលៃទុកពូជ ការលក់ដូរក្នុងតម្លៃសមស្រប និងបន្តអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៩ សរណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចាត់វិធានការថែរក្សាទឹកទុក។

ដោយឡែក ក្រុមការងារទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤របស់រដ្ឋបាលព្រៃឈើ បានខិតខំចុះល្បាត រុករកបទល្មើសព្រៃឈើយ៉ាងសកម្មក្រោមកិច្ចសហការជាមួយកងកម្លាំងប្រដាប់អាវុធតាមបណ្តាខេត្តនីមួយៗ។ ម្យ៉ាងទៀត ក្រសួងក៏បានចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសផលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពខេត្តផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានសម្រាប់ខែមករា ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៥២៩.៧៦៧ហិកតា តិចជាងឆ្នាំមុនចំនួន៣៦.១៩៩ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន១៧.១០០ហិកតា ស្មើនឹង៣,២៣% និងគ្រឿងយន្តចំនួន៥១២.៦៦៧ហិកតា ស្មើនឹង៩៦,៧៧%
- ផ្ទៃដីសាបសម្រេចបានចំនួន១.១៦២ហិកតា តិចជាងឆ្នាំមុនចំនួន២.៨៥៣ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន៤៨៣.១៥៥ហិកតា ស្មើនឹង១១៥,៧៧% នៃផែនការ៤១៧.៣២៥ហិកតា លើសឆ្នាំមុនចំនួន៤.០៩១ហិកតា។



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំងឆ្នាំ២០១៥-២០១៦

ការងារប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន១៣៣.៤៣៥ហិកតា ស្មើនឹង២៧,៦២% នៃផ្ទៃដីអនុវត្តចំនួន ៤៨៣.១៥៥ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៥៧៧.៣៥៥តោន និងទិន្នផលជាមធ្យមចំនួន៤,៣២៧ តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន១៦៨គីឡូក្រាមក្នុងមួយហិកតា។

### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៧៣.២១៩ហិកតា ស្មើនឹង១៧១,៤៨% នៃផែនការ៤២.៦៩៨ហិកតា លើសឆ្នាំមុនចំនួន៥.២៥៩ហិកតា
- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន១២.១៩៥ហិកតា ស្មើនឹង៥៩,៩៨%នៃផែនការ២០.៣៣១ហិកតា តិចជាងឆ្នាំមុនចំនួន១.២០៦ហិកតា។

### ១.៤ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាសម្រាប់ខែមករា ឆ្នាំ២០១៦នេះ មានបរិមាណចំនួន៤៤.០៣៣តោន ដែលមានការកើនឡើងចំនួន៨.១១២តោន(+២២,៦%) លើសបរិមាណនាំចេញក្នុងខែមករា ឆ្នាំ២០១៥ ដែលមានតែ ៣៥.៩២១តោន និងបាននាំចេញទៅកាន់ទិសដៅចំនួន៣៥ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១(៦.៩៩៩តោន) ប្រទេសបារាំងឈរលំដាប់ទី២(៦.៣៨៦តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣(៥.៥៣៨តោន) ប្រទេសរ៉ូមានីឈរលំដាប់ទី៤(២.៧៦៤តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៥(២.៧៣៦តោន) ប្រទេសនីឌ័រឡេនឈរលំដាប់ទី៦(២.៥០៣តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧(២.០៧៤តោន) ប្រទេសព្រុយណេឈរលំដាប់ទី៨(១.៩៧៤តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៩(១.៩១២តោន) និងប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី១០(១.០៦៣១តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហគមន៍អឺរ៉ុប២០ប្រទេស មានបរិមាណសរុប២៩.៨៩៦តោន(៦៧,៩%) ទិសដៅអាស៊ាន៣ប្រទេស មានបរិមាណសរុប៥.១២៨តោន(១១,៦%) និងទិសដៅផ្សេងទៀតចំនួន១២ប្រទេសមានបរិមាណសរុប៩.០០៩តោន(២០,៥%)។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអភិវឌ្ឍន៍ ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨ | ៧៥៧ | ៧៣ | - |
| សរុប I | | ៥០៨ | ៧៥៧ | ៧៣ | - |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨ | ១៦.០២៨ | ៣.២២៦ | ១.៦៨០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់បើលីមីធីត (រតនគិរី) | ៧៩ | ២.៤៩៨ | ៣២២ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២.១០១ | ១៧៧ | - |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៣២៨ | ៥.៣៩៤ | ៥.៨៦៧ | ១៤៧ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៩ | ៨.៦៦១ | ៦៦៣ | ២៧៧ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វូវីសេសស៍ (ស្នួល) | ១.៧៤៥ | ៤.៣៦៥ | ៥០៤ | ៣០០ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង,មាសហែក) | ១.៨៨២ | ៣.៣៩០ | ២៣៨ | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.៣២៧ | ៥.៩២៤ | ២៩៧ | - |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦ | ៥.៧៣១ | ១.០៣៦ | ៤០៦ |
| សរុប II | | ២៨.៤៩៤ | ៥៤.០៩២ | ១២.៣៣០ | ២.៨១០ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៥.៧៣៥ | ១៨៤.២៥២ | ៤៣៦ | ៤៣៦ |

| | | | | | |
|---|---|---|---|---|---|
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៦.៤៩៦ | ១៤៩.៨៥៣ | ១៤.៤០៧ | ៦.៧០៧ |
| សរុប III | | ៨២.២៣១ | ៣៣៤.១០៥ | ១៤.៨៤៣ | ៧.១៤៣ |
| សរុប I+II+III | | ១១១.២៣៣ | ៣៨៨.៩៥៥ | ២៧.២៤៦ | ៩.៩៥៣ |

- គួរកត់សម្គាល់ថា សម្រាប់ខែមករា ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.១៤៨ដុល្លារក្នុងមួយតោន។

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមប្រជុំពិភាក្សាការងារស្តីពីដំណើរការគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា

- ក្រុមការងារច្បារពូជកៅស៊ូចុះបេសកកម្មជាមួយការ CIRAD (ប្រទេសបារាំង) ទៅខេត្តប៉ៃលិន សៀមរាប ព្រះវិហារ រតនគិរី និងខេត្តមណ្ឌលគិរី ដើម្បីត្រួតពិនិត្យនិងផ្តល់អនុសាសន៍លើការងារថែទាំច្បារពូជ

- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន៤០ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់ក្រុមហ៊ុន ឡុង ស្រេង និងក្រុមហ៊ុន DTC ព្រមទាំងតេស្តកៅស៊ូសន្លឹកស្លានីយពិសោធន៍វិទ្យាស្ថាន

- វិភាគលទ្ធផលនៃការធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិលើកទី១១៣ ជាមួយ IRA (International Rubber Association)

- បន្តតាមដានទិន្នន័យគ្រប់ចម្ការពិសោធន៍ទាំងក្នុងនិងក្រៅស្ថានីយ

- ចុះស្រង់ ត្រួតពិនិត្យទិន្នន័យទឹកជ័រគ្រប់ចម្ការពិសោធន៍ និងស្រង់ទិន្នន័យឧតុនិយម Sap flow and Flux Tower

- រៀបចំទីតាំងស្រង់ទិន្នន័យជំងឺ Oidium ក្នុងឡូត៍ពិសោធន៍តួននៅចម្ការកៅស៊ូក្រែក ខេត្តត្បូងឃ្មុំ

- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូដល់កសិករបានចំនួន៨វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន២១៣នាក់

- បន្តបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ និងដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប។

# ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

៣.១ ការងារផលិតកម្ម៖ បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត ការរៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- ការងារកែលម្អពូជ៖ ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

- ការងារឡជីវឧស្ម័ន៖ ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១៨៣ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបានចំនួន២៥០ឡ។

- ចំណីសត្វ៖ បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- ការងារដំណាំចំណីសត្វ៖ តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថ

ប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

៣.២ ការងារបសុព្យាបាល

• លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

ខេត្ត-រាជធានីចំនួន១២ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន៣.៦៩២លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន១៤,៩គីឡូក្រាម និងឃាត់ចាប់បទល្មើសដឹកជញ្ជូនមាន់រស់លួចនាំចូលចំនួន៥.០៩៦ក្បាល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

• ការងារសុខភាពសាធារណៈ៖ ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានជាប្រចាំឱ្យស្របតាមលក្ខណៈបច្ចេកទេស។

• ការងារនីតិកម្មនិងវិវាទ៖ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានព្រឹទ្ធសភាពិនិត្យនិងអនុម័តនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ហើយត្រូវបាន ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្តលេខាដាក់ឲ្យប្រើប្រាស់ជាផ្លូវការតាមព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦។

៣.៣ ការងារស្រាវជ្រាវ៖

• ការងារស្រាវជ្រាវផលិតកម្ម៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំកាម៉ៅមានគោសរុបចំនួន១៦១ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣៣ក្បាល គោជំនង់៣៨ក្បាល គោមេបង្កាត់៤៨ក្បាល គោកំផែងសែន៤៣ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២១៤ក្បាល ក្នុងនោះជ្រូកបាចំនួន៤ក្បាល ជ្រូកមេ៥១ក្បាល កូនជ្រូក៦៨ក្បាល មេជ្រូកត្រៀមលក់ចំនួន១៥ក្បាល កូនជ្រូកលក់៥០ក្បាល កូនជ្រូកងាប់ចំនួន៨ក្បាល និងកូនជ្រូកទុកបម្រុងចំនួន១៨ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

• ការងារស្រាវជ្រាវបសុព្យាបាល៖ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងខែមករា ឆ្នាំ២០១៦នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន៣០០វត្ថុវិភាគ។

៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖ ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ វិស័យព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- លើកគម្រោងថវិកាសម្រាប់ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០១៦ នៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន៤គឺ ខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ ខណ្ឌរដ្ឋបាលព្រៃឈើកំពត ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី និងខណ្ឌរដ្ឋបាលព្រៃឈើព្រៃវែង

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន១០សហគមន៍ព្រៃឈើគ្របដណ្តប់លើផ្ទៃដីទំហំសរុប២.១២៤ហិកតា នៅក្នុងខេត្តសៀមរាបចំនួន៨សហគមន៍ព្រៃឈើដែលមានផ្ទៃដីទំហំ១.០៧៥

ហិកតា ខេត្តស្ទឹងត្រែងចំនួន១សហគមន៍ព្រៃឈើដែលមានផ្ទៃដីទំហំ៦១២ហិកតា និងខេត្តរតនគិរីចំនួន១សហគមន៍ព្រៃឈើដែលមានផ្ទៃដីទំហំ៤៣៣ហិកតា

- កំពុងពិនិត្យសេចក្តីព្រាងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១៥កន្លែង ក្នុងនោះខេត្តកំពង់ស្ពឺចំនួន៦កន្លែង ខេត្តពោធិ៍សាត់ចំនួន២កន្លែង ខេត្តក្រចេះចំនួន៣កន្លែង និងខេត្តរតនគិរីចំនួន៤កន្លែង

- សម្របសម្រួលប្រជុំប្រចាំត្រីមាសទី៤ ឆ្នាំ២០១៥ របស់គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ខេត្តចំនួន២ គឺខេត្តក្រចេះ ដែលមានអ្នកចូលរួមចំនួន៤៦នាក់ ក្នុងនោះស្ត្រីចំនួន៥នាក់ និងខេត្តព្រះវិហារ ដែលមានអ្នកចូលរួមចំនួន១០៨នាក់ ក្នុងនោះស្ត្រីចំនួន៧នាក់។

## ៤.២ ការងារអភិរក្សសត្វព្រៃ

- បានបញ្ជូនសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាំង ទៅទីស្តីការគណៈរដ្ឋមន្ត្រី

- រៀបចំអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ ព្រះរការ ដែលមានផ្ទៃដីទំហំ៩២.១៣២ហិកតា ស្ថិតនៅក្នុងខេត្តព្រះវិហារ

- តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម តំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប និងតំបន់ព្រៃការពារព្រះវិហារ បានទទួលភ្ញៀវទេសចរណ៍បរទេសមកទស្សនាចំនួន១២៥នាក់

- ធ្វើការអង្កេតកក់ក្រាសត្វស្លាបប្រចាំឆ្នាំនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤ (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ដោយបានរកឃើញសត្វស្លាបចំនួន១៤៩ប្រភេទ ប្រហែលជា៤៨.៧៤៧ក្បាល

- ចុះប្រមូលសំណាកសត្វប្រចៀវរស់ចំនួន១៩៧ក្បាល ក្នុងនោះមានសត្វព្រីងចំនួន៣១ក្បាល ដែលស្មើនឹង ៥៩១សំណាក ដើម្បីធ្វើការពិនិត្យទៅលើការបន្តពូជ ការយកឈាម លាមក ទឹកមាត់ ទឹកនោម វាស់ប្រវែងស្លាប និងវិភាគរកមេរោគ

- ផ្តល់ចំណីដល់សត្វត្មាតនៅខេត្តស្ទឹងត្រែង-ក្រចេះ ព្រៃការពារសៀមប៉ាង និងតំបន់ព្រៃការពារព្រះវិហារ ដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការអង្កេតតាមដាន ដោយរាប់ឃើញត្មាតសរុបចំនួន៤៣ក្បាល

- ធ្វើការការពារសម្បុកសត្វត្រដក់តូចចំនួន១០សម្បុក សម្បុកសត្វត្មាតចំនួន៣សម្បុកនៅខេត្តស្ទឹងត្រែង ក្រចេះ និងព្រះវិហារ។ ការពារសំបុកសត្វដើម្បីធានាសុវត្ថិភាពពងកូន ពីព្រោះសំបុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ

- ក្រុមការងារបានចុះប្រមូលសំណាកលាមកដំរី (លាមកស្រស់) នៅតំបន់ជួរភ្នំក្រវាញបានចំនួន៤៥សំណាក សម្រាប់យកទៅវិភាគ DNA ដើម្បីកំណត់ចំនួនដំរីព្រៃនៅក្នុងតំបន់សិក្សា និងចុះអន្តរាគមន៍ជួយដល់ប្រជាពលរដ្ឋនៅជីផាត (កោះកុង) ដែលទទួលរងនូវការបំផ្លិចបំផ្លាញដំណាំពីសត្វដំរី។

## ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជធម្មជាតិ និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែមករា ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន៦៩ក្បាល សត្វកើតថ្មីចំនួន៣ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន៨៧ក្បាល សត្វស្លាប់ចំនួន១៤ក្បាល ព្យាបាលសត្វចំនួន៣៨ក្បាល យកសំណាកទៅពិសោធន៍ចំនួន២ក្បាល ធ្វើឱ្យសន្លប់ចំនួន៥ក្បាល វះកាត់សាកសពសត្វចំនួន១៣ក្បាល សាងសង់របងហ៊ុំព័ទ្ធចំនួន១.២០០ម$^2$ ជួសជុលផ្លូវចំនួន១៩.៤០០ម$^2$ សាងសង់សំណង់ផ្សេងៗចំនួន៧០០ម$^2$ កាប់ឆ្ការអនាម័យព្រៃចំនួន៧.២៨៣ម$^2$ និងអប់រំផ្សព្វផ្សាយសិស្សនិស្សិតចំនួន៤៣៧នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្ដាមចំនួន៥៤.៨៤៨ក្បាល និងនាំចេញកូនស្វាក្ដាមជំទង់ចំនួន២.៨៧២ក្បាល។

## ៤.៤ ការងារដាំដើមឈើ

- បណ្តុះពូជឈើគ្រប់ប្រភេទបានចំនួន៨១.០៣៤ដើម និងចែកជូនប្រជាពលរដ្ឋដាំបានចំនួន៦.៣១៦ដើម

- បាននិងកំពុងជ្រើសរើសទីតាំង ដើម្បីអនុវត្តការងារអភិរក្សធនធានសេនេទិក តាមរយៈការបង្កើតជាចម្ការពូជ/៤

ប្រភេទឈើក្នុងស្រុក (ផ្ចឹក) និងមានផែនការអនុវត្តលើផ្ទៃដីទំហំ១០ហិកតា នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលឆាយ ខេត្តព្រះសីហនុ

- ក្រុមការងារស្រាវជ្រាវនិងកំណត់អត្តសញ្ញាណសត្វល្អិត L.invasa (Leptocybe invasa) បានធ្វើការតាមដាន និងស្រាវជ្រាវជាបន្តទៀត តាមរយៈការចុះប្រមូលសំណាកដើមប្រេងខ្យល់តាមបណ្តាឡូត៍គំរូនៅបណ្តាខេត្តមួយចំនួននៅតំបន់ឆ្នេរដូចជា ខេត្តតាកែវ កំពត ព្រះសីហនុ និងខេត្តកំពង់ស្ពឺ។ ជាលទ្ធផល ក្រុមការងារបានប្រមូលសំណាកចំនួន១០សំណាកថង់ប្លាស្ទិច នៃសត្វល្អិត L.invasa នៅក្នុងចម្ការប្រេងខ្យល់ក្នុងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ។

## ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- រៀបចំចុះបញ្ជិកា និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់ជូនអតិថិជន និងក្រុមហ៊ុន ដែលមានរណារយន្តចំនួន១១គ្រឿង និងយានយន្តចំនួន១០គ្រឿង

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុនចំនួន៥ និងអតិថិជន៣នាក់ ដែលមានឈើហ៊ុបមូលចំនួន៤.១៥៥ម$^{៣}$ ឈើអារចំនួន១.០០៤ម$^{៣}$ ឈើជ្រុងចំនួន១៤២ម$^{៣}$ កូនឈើចំនួន៥៣.២២៧ដើម អុសចម្រុះចំនួន១១.២៥០ស្ទែរ ជ័រទឹកចំនួន២៨០តោន និងពកបេងចំនួន៥៥៨គីឡូក្រាម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន១ក្រុមហ៊ុន ដែលមានបរិមាណសរុប៤០០ម$^{៣}$

- រៀបចំសំណើសុំពន្យារគោលការណ៍នាំចេញចំនួន១ក្រុមហ៊ុន ដែលមានផលិតផលឈើដើមចន្ទន៍ក្រស្នាចំនួន១០០តោន(ឈើស្រាយស) ឈើគុចំនួន២០០គីឡូក្រាម និងប្រេងចន្ទន៍ក្រស្នាចំនួន៥០គីឡូក្រាម

- ចុះពិនិត្យការស្នើសុំបង្កើតរោងម៉ាស៊ីនអារ-កែច្នៃឈើ ជូនក្រុមហ៊ុនចំនួន២

- រៀបចំលិខិតស្នើសុំបង្កើតរោងម៉ាស៊ីនអារ-កែច្នៃឈើជូនចំនួន ១ក្រុមហ៊ុន

- ផ្តល់សៀវភៅកត់ត្រាចរាចរផល អនុផលព្រៃឈើ និងផលិតផលឈើចូល-ចេញ សម្រាប់ឆ្នាំ២០១៦ ជូនខណ្ឌ និងផ្នែករដ្ឋបាលព្រៃឈើចំនួន ១០៨ក្បាល

- ផ្តល់លិខិតសម្រាប់ខណ្ឌរដ្ឋបាលព្រៃឈើបំពេញលើករណីបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន២៨៥សន្លឹក និងបង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើចំនួន១១៥សន្លឹក ជូនខណ្ឌរដ្ឋបាលព្រៃឈើចំនួន៥។

## ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែមករា ឆ្នាំ២០១៦នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន៤៨.៥៤០.០០០រៀល និងចំណូលពីសេវាសាធារណៈចំនួន១៦៧.៣១៣.៧០២រៀល និង១.៨៧៦,៤០ដុល្លារ។

## ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែមករា ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៤៣ករណី ដោយបញ្ជូនទៅតុលាការចំនួន១១៤ករណី និងពិន័យអន្តរការណ៍ចំនួន២៩ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១៦៩ម$^{៣}$ ឈើអារចំនួន២២២ម$^{៣}$ ឈើក្រាក់គ្រញូងចំនួន១១ម$^{៣}$ និង២៥គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៤១៩ក្បាលនិង១៥២គ.ក្រ អនុផលព្រៃឈើ សម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៤០៦ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន៩៣ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានផ្ញើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន២៥ករណី

- សហការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ។ ដោយឡែក ក្រុមការងារទប់ស្កាត់និងបង្ក្រាបបទ

ល្មើសព្រៃឈើនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤បានខិតខំចុះល្បាត រុករកបទល្មើសព្រៃឈើយ៉ាងសកម្ម ក្រោមកិច្ចសហការជាមួយកងកម្លាំងប្រដាប់អាវុធតាមបណ្ដាខេត្តនីមួយៗ។

## ៥ ផ្នែកជលផល

### ៥.១ ផលិតកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន១.០៥០តោន ស្មើនឹង៨,៧៥% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៩.៩៥០តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន២៣.០០០តោន ស្មើនឹង៦,៦៩% នៃផែនការ៣៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៧.០០០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន៨.០០០តោន ស្មើនឹង៥,៥៦% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២.០០០តោន

- គួរកត់សម្គាល់ថា ក្នុងខែមករា ឆ្នាំ២០១៦នេះ ស្ថានភាពទឹកទន្លេស្រកលឿនជាងបណ្ដាឆ្នាំមុនៗ។ បច្ចុប្បន្ន នៅស្ថានីយចតុមុខ ទឹកមានកម្ពស់២,៣៥ម ប្រៀបធៀបពេលដូចគ្នាក្នុងខែមករា ឆ្នាំ២០១៥ ទន្លេចតុមុខមានកម្ពស់២,៦៣ម។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន៦.៥០០តោន ស្មើនឹង៥,៩១% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១.៥០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន៨.៥០០តោន ស្មើនឹង៤,៩២% នៃផែនការ១៧២.៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៥០០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន៨.២០០ក្បាល ស្មើនឹង៣,២៨% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២០០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ១០.០០០.០០០កូន ស្មើនឹង៥,៥៦% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួនប្រមាណ១.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន៥.៥០០តោន ស្មើនឹង៦,៧១% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៥០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន៧៥០តោន ស្មើនឹង៩,៣៨% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៥០តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន២.៥០០.០០០លីត្រ ស្មើនឹង៥% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៥០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន៩០០តោន ស្មើនឹង៦% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១០០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន៤០០តោន ស្មើនឹង៨% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ខែមករា ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន២៨៥ករណី ក្នុងនោះរឹបអូសបណ្ដោះអាសន្ន រុះរើនិងបំផ្លាញចោលវត្ថុតាងចំនួន២៥៧ករណី បញ្ជូនទៅតុលាការចំនួន១៤ករណី ដោយបញ្ជូនជនសង្ស័យទៅតុលាការចំនួន២៨នាក់ ជាប់ពន្ធនាគារចំនួន១៩នាក់ និងពិន័យអន្តរការណ៍ចំនួន១៤ករណី ស្មើនឹងទឹកប្រាក់ចំនួន

៨.៤០០.០០០រៀល

- បានផ្សព្វផ្សាយច្បាប់ស្ដីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន២វគ្គ ដោយមានអ្នកចូលរួមចំនួន១៥៣នាក់

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៧២.៨១៤ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន១២.៨២៥មាត់ បង្គោល/ចម្រឹងចំនួន៤១.៧៣៩ដើម ឧបករណ៍នេសាទត្រីចំនួន៣២គ្រឿង សម្រាស់ចំនួន៧.៩៣០ម៉ែត្រក្រឡា របាំងព្រួលប្រវែង៦៤៤ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្ដុរ/ពោះវៀនជ្រូក)ចំនួន២០គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៣.៧៣៧គ.ក្រ

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព រួមទាំងការទប់ស្កាត់ការលួចចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោ និងការចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពខេត្ត។

### ៥.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផល សម្រាប់ឆ្នាំ២០១៥សរុបបានចំនួន៤.១៥០.៥៨៥.៧៥៧រៀល ស្មើ១១៦,៧៨% នៃផែនការ៣.៥៥៤.២៨១.២៥០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.០៥៩.៣៧៦.១៥៧រៀល។

## ៦ ផ្នែកមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះសម្ភាសន៍កសិករស្ដីពីសុវត្ថិភាពអាហារ និងសម្ភាសន៍អាជីវករស្ដីពីខ្សែចង្វាក់ផ្គត់ផ្គង់ដំណាំបន្លែ នៅខេត្តកណ្ដាល

- ចុះសម្ភាសន៍កសិករស្ដីពីការប្រើប្រាស់គ្រឿងយន្តកសិកម្ម នៅខេត្តតាកែវ និងខេត្តកំពត

- ចុះត្រួតពិនិត្យការងារពិសោធន៍បន្លែមុនពេលប្រមូលផល នៅខេត្តកំពត

- ចុះរៀបចំធ្វើពិសោធន៍និងត្រួតពិនិត្យការងារពិសោធន៍នៅខេត្តតាកែវ ខេត្តកំពត និងនៅស្ថានីយស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍

- ចូលរួមប្រជុំបូកសរុបការងារប្រចាំឆ្នាំនៃគម្រោង នៅខេត្តបាត់ដំបង និងពិនិត្យឡសម្ងួត នៅខេត្តតាកែវ។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន៣២៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន៣២០ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៧៨ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៦១៧ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរ សរុបចំនួន១០៥ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន៣៥ច្បាប់ និងផ្ដល់ទិដ្ឋាការបេសកកម្មមន្ត្រីមន្ទីរកសិកម្មរាជធានី ខេត្តចំនួន៧៨ច្បាប់ សរុបមនុស្ស១២៦នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិៗល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៥៦០នាក់ នារីចំនួន១.៣៨៣នាក់ ស្មើនឹង២១% រួមមាន៖

+ អង្គភាពថ្នាក់កណ្ដាលចំនួន៤.០២១នាក់ ក្នុងនោះនារីចំនួន៨១៣នាក់ ស្មើនឹង២០%

+ អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៣៩នាក់ ក្នុងនោះនារីចំនួន៥៧០នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៥នាក់ ក្នុងនោះសុំលាឈប់ពីការងារចំនួន៣នាក់ និងមរណភាពចំនួន២នាក់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន០៩នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន៨នាក់ និងសុំច្បាប់ព្យាបាលជំងឺចំនួន១នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចូលក្នុងក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៧នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៤៦នាក់ និងចូលធ្វើការងារវិញចំនួន២៣នាក់

- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន០៨នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៤១៥រូប នៅប្រទេសចំនួន៣០

- បានស្នើសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសុំបញ្ជូនគម្រោង "Improvement of Commune Level Agricultural Extension System and Rural Development" ទៅសាធារណរដ្ឋកូរ៉េ

- អន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីផ្តល់គម្រោងផែនការរំកិល (២០១៦-២០១៨) ស្តីពី "ផែនការសកម្មភាពមេគង្គ-ជប៉ុន សម្រាប់អនុវត្តយុទ្ធសាស្ត្រក្រុងតូក្យូថ្មី២០១៥"

- ស្នើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់សុខភាពសត្វ និងជំងឺស៊ូណូស(Agreement on the Esta-blishment of the ASEAN Coordinating Centre for Animal Health and Zoonose-ACCAHZ) និងគោលការណ៍បង់វិភាគទានសម្រាប់ប្រទេសជាសមាជិក

- អន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំប័ណ្ណសម្គាល់និងស្លាកលេខONG សម្រាប់រថយន្តចំនួន១គ្រឿង និងម៉ូតូចំនួន១គ្រឿង ជូនអង្គការហេក្ស (HEKS) និងម៉ូតូចំនួន១៧គ្រឿងជូនអង្គការសមាគមអភិរក្សសត្វព្រៃ(WCS)

- រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការ WE EFFECT ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

## ១០ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន៩៩៤នាក់ (ស្ត្រី៣៥០នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន៧៥១នាក់(ស្ត្រី២៨២នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២៤៣នាក់(ស្ត្រី៦៨នាក់)។

និស្សិតសរុបមានការប្រែប្រួលថយចុះបន្តិចដោយសារនិស្សិតបានបញ្ចប់ការសិក្សាមានចំនួនច្រើនជាងនិស្សិតចូលថ្មី។ សាលាជាតិកសិកម្មព្រែកលៀបបានទទួលនិស្សិតថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាននិងបរិស្ថាន(ថ្នាក់បរិញ្ញាបត្ររងអាហា-រូបករណ៍)ឲ្យចូលរៀនសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦។ ពិនិត្យកែតម្រូវលើ Proposal របស់និស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ គ្រប់ជំនាញ និងបញ្ជូននិស្សិតចុះកម្មសិក្សាសម្រាប់សរសេរសារណាបញ្ចប់ការសិក្សា។ សាលាជាតិកសិកម្មព្រែកលៀបបានចុះពិនិត្យ តាមដាន និងរារាំងការទន្ទ្រានយកដីរបស់សាលានៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន (Japonica seeds) ព្រមទាំងបន្លែនៃពូជយកពីជប៉ុន និងរៀបចំបញ្ជូននិស្សិតចំនួន២នាក់ទៅធ្វើកម្ម-សិក្សានៅប្រទេសជប៉ុន។ សាលាជាតិកសិកម្មព្រែកលៀបបាននឹងកំពុងសាងសង់រោងពិសោធន៍ចំនួន៣ សម្រាប់ការដាំដំណាំ និងបន្លែពិសោធន៍នៅក្នុងបរិវេណសាលាជាតិកសិកម្មព្រែកលៀប និងកំពុងដឹកនាំនិស្សិតដាំបន្លែក្នុងបរិវេណសាលា និងប្រភេទដំណាំមួយចំនួនបង្កើតជាភាពបៃតងដើម្បីកែលម្អសោភ័ណភាពរបស់សាលា។ បន្តសហការជាមួយគ្រូហ្វីលីពីនដើម្បីជំរុញការបង្រៀនភាសាអង់គ្លេសទៅតាមកម្រិត។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន៦៩៧នាក់(ស្ត្រី២៧៩នាក់) រួមមានៈ

- និស្សិតអាហារូបករណ៍សរុប៦៤៨នាក់ (ស្ត្រី២៦៣នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន៤៥៥នាក់(ស្ត្រី១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន១២៥នាក់(ស្ត្រី៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន៤៩នាក់ (ស្ត្រី១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន៣៨នាក់(ស្ត្រី១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផលដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

បញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ និងនិស្សិតថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មឆ្នាំទី២ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្តាអង្គការនានា។ បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគររកជំនួយ ក្នុងនោះកំពុងសហការជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងទំនាក់ទំនងជាមួយអង្គការ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសកូរ៉េ។ សហការជាមួយអង្គការ OISCA បញ្ជូននិស្សិតចុះជួយអប់រំសិស្សសាលាបឋមសិក្សានិងវិទ្យាល័យ នៅស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ អំពីបរិស្ថាន និងដាំដើមឈើតាមសាលារៀន។ បញ្ជូននិស្សិតជំនាញក្សេត្រ-សាស្ត្រចំនួន២នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន និងត្រៀមបញ្ជូននិស្សិតដែលបញ្ចប់ការសិក្សារួចទៅបន្តនៅឆ្នាំ២០១៦។ សហការជាមួយសាកលវិទ្យាល័យ SHIN JU ប្រទេសជប៉ុនក្នុងការផ្តល់ពូជដង្កូវនាងព្រៃ ជួយបណ្តុះបណ្តាលនិងរៀបចំមន្ទីរពិសោធន៍បាណកសត្វ និងសហការជាមួយ DTRA(Defence Threat Reduction Agency) បើកវគ្គអំពីអេពីឌេមីសាស្ត្រសត្វដល់និស្សិត និងមន្ត្រីជំនាញ។

## ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន៤.០៧៩នាក់(ស្ត្រី១.២២៤នាក់) បែកចេញជា១០មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានសហការជាមួយអង្គការ OXFAM America ក្នុងការបើកសិក្ខាសាលាបង្ហាញពីលទ្ធផលនៃការធ្វើតេស្តឧបករណ៍ស្ទូងស្រូវ ជូនដល់កសិករមកពីខេត្តតាកែវ និងនិស្សិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម សហការជាមួយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលធ្វើសិក្ខាសាលាស្តីពីការបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វលើប្រធានបទ បញ្ហាប្រឈមនិងដំណោះស្រាយ រយៈពេល៣ថ្ងៃនៅខេត្តកំពង់ចាម ជូនដល់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់។ សាកលវិទ្យាល័យបានសហការជាមួយ KOPIA កម្ពុជារៀបចំកិច្ចប្រជុំវាយតម្លៃគម្រោងចិញ្ចឹមមាន់របស់កសិករនិងប្រគល់គោយន្តចំនួន៣គ្រឿងជូនកសិករ នៅភូមិកំពង់ពោធិ៍ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល សហការជាមួយសាស្ត្រាចារ្យសាកលវិទ្យាល័យណាហ្គូយ៉ានៃប្រទេសជប៉ុនចំនួន១០នាក់ ដើម្បីដឹកនាំនិស្សិតជប៉ុនចំនួន៣៧នាក់ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន៣៧នាក់ចុះធ្វើកម្មសិក្សានៅខេត្តកណ្តាល និងខេត្តកំពង់ចាមចំនួន១សប្តាហ៍។ សាកលវិទ្យាល័យបានទទួលនិស្សិតនិងសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ Handong Global នៃប្រទេសកូរ៉េ មកធ្វើទស្សនកិច្ចនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន១០នាក់ និងបន្តកិច្ចសហប្រតិបត្តិការលើការងារបណ្តុះបណ្តាលនិងស្រាវជ្រាវផ្នែកកសិកម្មជាមួយសាកលវិទ្យាល័យ Yunnan នៃប្រទេសចិន ព្រមទាំងបានបញ្ជូនមន្ត្រីសាស្ត្រាចារ្យសរុបចំនួន៨នាក់ ទៅចូលរួមសិក្ខាសាលានិងកិច្ចប្រជុំនៅប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសជប៉ុន។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម ការងារបង្កបង្កើនផលស្រូវរដូវប្រាំងមានសន្ទុះលឿនជាងឆ្នាំមុន ដោយសម្រេចបានចំនួន៤៨៣.១៥៥

ហិកតា ស្មើនឹង១១៥,៧៧% នៃផែនការ៤១៧.៣២៥ហិកតា លើសឆ្នាំមុនចំនួន៤.០៩១ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា ហើយប្រជាកសិករបាននឹងកំពុងដំណើរការប្រមូលផលជាបណ្តើរៗដោយទទួលបានបរិមាណផលសរុបចំនួន ៥៧៧.៣៥៥តោន និងទិន្នផលជាមធ្យម៤,៣២៧តោន/ហិកតា។ ទន្ទឹមនឹងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងបន្តជំរុញការណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀត ព្រមទាំងជួយអប់រំណែនាំប្រជាកសិករឲ្យបន្តយកចិត្តទុកដាក់អំពីការបាត់បង់បរិមាណ និងគុណភាពផលស្រូវមុននិងក្រោយពេលប្រមូលផលនិងរៀបចំរក្សាទុកដាក់ផលស្រូវឲ្យបានល្អ ដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារ ការលៃទុកពូជ និងការលក់ដូរក្នុងតម្លៃសមស្រប ព្រមទាំងខិតខំជំរុញការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការចាត់វិធានការថែរក្សាទឹកទុកឲ្យបានល្អសម្រាប់ការផ្គត់ផ្គង់នៅក្នុងរដូវប្រាំងនេះរហូតដល់ពេលមានភ្លៀងធ្លាក់។

ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល គឺស្ថិតនៅតែជាប្រធានបទអាទិភាព ដែលអង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាពិសេស ចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំសារាចរណែនាំបន្ថែមទៀតអំពីការការពារ ទប់ស្កាត់ភ្លើងឆេះព្រៃនៅក្នុងរដូវប្រាំងនេះ។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៦នេះ ព្រមទាំងបានបង្កើតក្រុមការងារតាមដាន ស្រង់ព័ត៌មានបណ្តាញសង្គម(ហ្វេសប៊ុក) របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានពាក់ព័ន្ធវិស័យកសិកម្ម ដើម្បីធ្វើការឆ្លើយតបនិងដោះស្រាយជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលា។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

យោងលើស្ថានភាពអាកាសធាតុដូចបានព្យាករណ៍ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តចាត់វិធានការផ្សព្វផ្សាយដល់គ្រប់អង្គភាពក្រោមឱវាទទាំងអស់ ដើម្បីអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ សរណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ដែលបានធ្វើការណែនាំដូចតទៅ៖

១-ការងារបង្កបង្កើនផលស្រូវប្រាំងក្នុងឆ្នាំនេះ(២០១៥-២០១៦) គឺអាចធ្វើបានតែ១ដងប៉ុណ្ណោះ ដោយមិនអាចធ្វើស្រូវប្រាំងលើកទី២បានទេ ទោះបីជាទឹកតាមបណ្តាអាងដែលបានរក្សាទុកនិងកន្លែងមួយចំនួនដែលមានទឹកធម្មជាតិក៏ដោយ គួរតែប្រើរក្សាទឹកទាំងនោះសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងការដាំដំណាំរួមផ្សំផ្សេងទៀតក្រៅពីស្រូវ។

២-ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមចាត់វិធានការថែរក្សាទឹកទុកឲ្យបានល្អ ដើម្បីផ្គត់ផ្គង់សម្រាប់តែការប្រើប្រាស់ប្រចាំថ្ងៃតែប៉ុណ្ណោះរហូតដល់ពេលមានភ្លៀងធ្លាក់។

ទន្ទឹមនឹងនេះ អង្គភាពជំនាញពាក់ព័ន្ធនីមួយៗត្រូវ៖

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតចង្រៃជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវប្រាំងនេះឱ្យបានសម្រេចតាមផែនការ
- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែន
- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដោយជំរុញកសិករឱ្យធ្វើការដាំដុះស្រូវស្រាល ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះ

រាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្ដែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្ដល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- ជំរុញការរៀបចំសន្និបាតកសិករ និងសន្និបាតកសិកម្មទូទាំងប្រទេសនាពេលខាងមុខ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦-២០១៧

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្ដាខេត្តដែលមានសក្ដានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្ដាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បច្ចុប្បន្ននេះ ដោយមានការធ្លាក់ចុះនៃតម្លៃកៅស៊ូនៅលើទីផ្សារដែលធ្វើឱ្យម្ចាស់ថ្នាលពូជកៅស៊ូសម្រេចចិត្តដកចេញនូវថ្នាលពូជរបស់ខ្លួន ហើយកសិករមួយចំនួនទៀតបានកាប់ដើមកៅស៊ូចោលនិងដាំដំណាំផ្សេងៗជំនួសវិញ។ ក្រសួងបានជំរុញឱ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឱ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្ដល់ក្ដីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

២ ផ្នែកផលិតកម្មនិងបសុព្យាបាល :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺផ្ដាសាយបក្សី ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាត់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្ដែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះដាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្ដារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្ដារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺផ្ដាសាយបក្សី ប៉េស្ដ ជំងឺផ្ដាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្ដាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

៣ ផ្នែកព្រៃឈើ :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

៤ វិស័យជលផល :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយុទ្ធការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដីកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ក្រុមពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- បន្តចាត់វិធានការក្នុងការទប់ស្កាត់ និងលុបបំបាត់ការចិញ្ចឹមត្រីឆ្តោនិងត្រីរ៉ស់ ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិឲ្យបានហ្មត់ចត់ប្រកបដោយប្រសិទ្ធភាពខ្ពស់

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទជាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

៥ វិស័យពាក់ព័ន្ធផ្សេងៗ :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយៗ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្ដែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្ដុះបណ្ដាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តរៀបចំការធ្វើវិសោធនកម្មច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននិងនៅក្នុងតំបន់ផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៦

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន